# សៀវភៅអនុវត្ត
# ជំនាញក្នុងការសរសេរលិខិតរដ្ឋបាល



មករា ២០១៣

គាំទ្រថវិកាដោយ៖ Australian Aid

**អ្នកពិនិត្យ**
អង្គការជនពិការកម្ពុជា

**រក្សាសិទ្ធិដោយ**
© 2013, អង្គការជនពិការកម្ពុជា

**អភិវឌ្ឍដោយ**
លោក គី សុផាន់/ប្រធានគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាល
អង្គការជនពិការកម្ពុជា

អ. ផេង ផារ៉ូហ្ស៊ីន/ប្រធានគ្រប់គ្រងកម្មវិធី
អង្គការជនពិការកម្ពុជា

**អាសយដ្ឋានទំនាក់ទំនង**
វត្តថាន់ មហាវិថីព្រះនរោត្តម សង្កាត់ ទន្លេបាសាក់
ខ័ណ្ឌចំការមន ភ្នំពេញ
កម្ពុជា
ប្រអប់សំបុត្រ ២០០៨
អ៊ីម៉ែល៖ admin@cdpo.org
គេហទំព័រ៖ www.cdpo.org

# សៀវភៅអនុវត្ត
# ជំនាញក្នុងការសរសេរលិខិតរដ្ឋបាល

## មាតិកា


**សេចក្តីផ្តើម៖** ..... 5

**ជំហានទី ១ ៖ ការប្រើក្បាលលិខិត និងបាវចនា** ..... 6

**ជំហានទី ២ ៖ ការកំណត់លេខលិខិត** ..... 6

**ជំហានទី ៣ ៖ កាលបរិច្ឆេទលិខិត** ..... 6

**ជំហានទី ៤ ៖ អ្នកផ្ញើ** ..... 6

**ជំហានទី ៥ ៖ ការប្រើប្រាស់ពាក្យ (គោរព) ទៅអ្នកទទួល** ..... 7

**ជំហានទី ៦ ៖ អ្នកទទួល និង ឋានានុក្រម** ..... 7

**ជំហានទី ៧ ៖ កម្មវត្ថុ** ..... 8

**ជំហានទី ៨ ៖ យោង** ..... 8

**ជំហានទី ៩ ៖ ខ្លឹមសារអត្ថបទ** ..... 9

**ជំហានទី ១០ ៖ ឃ្លាបញ្ចប់ខ្លឹមសារលិខិត** ..... 9

**ជំហានទី ១១ ៖ ឃ្លាថ្លែងការគោរព** ..... 10

**ជំហានទី ១២ ៖ ហត្ថលេខា** ..... 11

**ជំហានទី ១៣ ៖ ការចំលងជូន** ..... 11

**ឧបសម្ព័ន្ធ ៖** ..... 11

ឧបសម្ព័ន្ធទី១៖ ប្លង់លិខិតរដ្ឋបាល ..... 12

ឧបសម្ព័ន្ធទី២៖ រង់នៃការប្រើប្រាស់ពាក្យ (គោរព) តាមឋានានុក្រមនៃអ្នកទទួល .......................... 12

ឧបសម្ព័ន្ធទី៣៖ ទំរង់ពាក្យគន្លឹះផ្ដើមលិខិត .......................................................................... 12

ឧបសម្ព័ន្ធទី៤៖ ពាក្យគន្លឹះបញ្ចប់ខ្លឹមសារលិខិត.......................................................................... 12

ឧបសម្ព័ន្ធទី៥៖ ឃ្លាថ្លែងការគោរព ........................................................................................ 12

# សៀវភៅអនុវត្ត
# ជំនាញក្នុងការសរសេរលិខិតរដ្ឋបាល

## សេចក្តីផ្តើម៖

ដោយមើលឃើញពីតំរូវការកសាងសមត្ថភាព ជាភាពចាំបាច់របស់អង្គការតំណាងជនពិការ សហព័ន្ធ វេទិកាស្ត្រីពិការ នានានៅក្នុងប្រទេសកម្ពុជាទៅលើជំនាញការងារ នៅបរិបទអភិវឌ្ឍ សមត្ថភាព ស្ថាប័នរបស់អង្គការតំណាងជនពិការ សហព័ន្ធ វេទិកាស្ត្រីពិការ ។ អង្គការជនពិការកម្ពុជា បានអភិវឌ្ឍ នូវសៀវភៅអនុវត្ត ជំនាញក្នុងការសរសេរលិខិតរដ្ឋបាល សំរាប់ជាជំនួយដល់ការព្រងឹង សមត្ថភាព ការងាររដ្ឋបាលសំរាប់ អង្គការតំណាងជនពិការ សហព័ន្ធ វេទិកាស្ត្រីពិការទាំងនោះ។

នៅក្នុងសៀវភៅអនុវត្តនេះ រួមមានជំហានទាំង ១៣ ក្នុងការសរសេរលិខិតរដ្ឋបាល រួមទាំង ឧបសម្ព័ន្ធ ដើម្បីជាជំនួយកាន់តែងាយស្រួលក្នុងការអនុវត្ត។

អង្គការជនពិការកម្ពុជាមានសុទិដ្ឋិនិយម លើសុឆន្ទៈរបស់បងប្អូនជនពិការ ក្នុងកសាងនិងពង្រឹង នូវចលនាពិការភាពប្រកបដោយភាពជឿនលឿន និងរីកចំរើនទៅមុខ ។

## ជំហានទី ១ ៖ ការប្រើក្បាលលិខិត និងបាវចនា

**ក. ក្បាលលិខិត៖**

- សំរាប់រាជរដ្ឋាភិបាល គឺដាក់ រូបសញ្ញារាជរដ្ឋាភិបាល
- រីឯ អង្គការ សមាគម គឺដាក់ ក្បាលលិខិតដែល មានសំរាប់ស្ថាប័ននីមួយៗ

**ខ. បាវចនា៖**

- សំរាប់រាជរដ្ឋាភិបាល គឺសរសេរថា៖

| |
|---|
| ព្រះរាជាណាចក្រកម្ពុជា<br>ជាតិ សាសនា ព្រះមហាក្សត្រ |

- រីឯ អង្គការ សមាគម មិនមានដាក់ បាវចនានេះទេ។

***សូមមើលឧបសម្ព័ន្ធទី ១ អំពី ប្លង់លិខិតរដ្ឋបាល***

## ជំហានទី ២ ៖ ការកំណត់លេខលិខិត

- ការកំណត់លេខលិខិតអាស្រ័យតាមស្ថាប័ន អង្គការនីមួយៗ។
- រាល់លេខលិខិតត្រូវចុះចូលក្នុងសៀវភៅ លិខិតរដ្ឋបាលចេញជានិច្ច។
- ឧទាហរណ៍៖ អ.ព.ក កំណត់៖ លេខ/ឆ្នាំ បូក អក្សរកាត់ ( ១២៩/១៣ អ.ព.ក)

## ជំហានទី ៣ ៖ កាលបរិច្ឆេទលិខិត

- កាលបរិច្ឆេទលិខិតត្រូវចុះនៅពេលលិខិតរដ្ឋបាលត្រូវបានចុះហត្ថលេខារួចហើយ។
- កាលបរិច្ឆេទលិខិតត្រូវចុះតាមលំដាប់លំដោយនៃលេខលិខិតផងដែរ។

## ជំហានទី ៤ ៖ អ្នកផ្ញើ

- ដាក់តែតួនាទី និង ឈ្មោះអង្គការបានហើយ។
- ឧទាហរណ៍៖ នាយកប្រតិបត្តិ អង្គការអភិវឌ្ឍជនពិការស្រុក...

## ជំហានទី ៥ ៖ ការប្រើប្រាស់ពាក្យ (គោរព) ទៅអ្នកទទួល

- ការប្រើប្រាស់ពាក្យ (គោរព)នេះមានសារសំខាន់ក្នុងការទំនាក់ទំនង
- ត្រូវជ្រើសរើស ពាក្យ ត្រូវ ទៅតាម ឋានៈ តួនាទីនៃអ្នកទទួល
- ឧទាហរណ៍៖ បើឋានៈ រដ្ឋមន្ត្រី ត្រូវរើសពាក្យ "សូមគោរពជូន" ។ បើឋានៈ ប្រធានការិយាល័យ ត្រូវរើសពាក្យ "សូមជម្រាបជូន"។

*<u>សូមមើលតារាង ទំរង់នៃការប្រើប្រាស់ពាក្យ (គោរព) តាមឋានានុក្រមនៃអ្នកទទួល(ឧបសម្ព័ន្ធទី ២)</u>*

## ជំហានទី ៦ ៖ អ្នកទទួល និង ឋានានុក្រម

- ប្រើ ឈ្មោះនិងងារ ពេញលេញ មិនសរសេរកាត់
- ដាក់មុខងារសាធារណរបស់អ្នកទទួលបន្ទាប់ពីឈ្មោះនិងងារ
- ដាក់ឈ្មោះស្ថាប័នពីមុខងារសាធារណរបស់អ្នកទទួល

**ក្នុងករណីដែលមិនស្គាល់ឈ្មោះអ្នកទទួល**

- ត្រូវដាក់ងារ
- ដាក់មុខងារសាធារណរបស់អ្នកទទួលបន្ទាប់ពីងារ
- ដាក់ឈ្មោះស្ថាប័នពីមុខងារសាធារណរបស់អ្នកទទួល

**ត្រូវចងចាំ៖**

- ជៀសវាងការសរសេរឈ្មោះនិងមុខងារច្រឡំ
- ត្រូវសួរពត៌មានបន្ថែមពីអ្នកដឹងច្បាស់លាស់ រឺស្រាវជ្រាវពត៌មាន

*<u>សូមមើលតារាង ទំរង់នៃការប្រើប្រាស់ពាក្យ (គោរព) តាមឋានានុក្រមនៃអ្នកទទួល(ឧបសម្ព័ន្ធទី ២)</u>*

## ជំហានទី ៧ ៖ កម្មវត្ថុ

- កម្មវត្ថុត្រូវ ខ្លី និងមានន័យគ្រប់គ្រាន់ ។
- ជៀសវាងការសរសេរកម្មវត្ថុវែង។
- កម្មវត្ថុ សរសេរយ៉ាងវែងបំផុតត្រឹម ៣បន្ទាត់ជាការស្រេច។
- សូមប្រើទំរង់បែបនេះក្នុងការសរសេរកម្មវត្ថុ៖
    - នរណា - សូមគោរពអញ្ជើញលោក ........ ប្រធានអង្គការតំណាងជនពិការ...
    - អ្វី - ចូលរួមប្រជុំកិច្ចបណ្តាញប្រចាំខែ
    - ពេលណា - នាថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០XX
    - នៅទីណា - នៅការិយាល័យ អង្គការជនពិការកម្ពុជា ។

ការសំរាយកម្មវត្ថុ ខាងលើ៖

កម្មវត្ថុ៖ សូមគោរពអញ្ជើញលោក ........ ប្រធានអង្គការតំណាងជនពិការ... ចូលរួមប្រជុំកិច្ចបណ្តាញប្រចាំខែ នាថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០XX នៅការិយាល័យ អង្គការជនពិការកម្ពុជា៕

## ជំហានទី ៨ ៖ យោង

- លិខិតរដ្ឋបាល ខ្លះអាចមានយោង ជាឯកសារ លិខិតនានា។
- នៅពេលមានយោងត្រូវអនុវត្តតាមវិធីនេះ៖
    - លិខិតលេខ៖ លិខិត លេខ ៨៦៨/១៣ អគគ
    - កាលបរិច្ឆេទលិខិត៖ ចុះថ្ងៃទី...ខែ..... ឆ្នាំ.......
    - ស្ថាប័ន៖ របស់អង្គការ............
    - កម្មវត្ថុនៃលិខិតយោង៖ ស្តីពី ...................

ការសំរាយយោង ខាងលើ៖

យោង៖ លិខិត លេខ ៨៦៨/១៣ អគគ ចុះថ្ងៃទី...ខែ..... ឆ្នាំ....... របស់អង្គការ............ ស្តីពី ...................។

## ជំហានទី ៩ ៖ ខ្លឹមសារអត្ថបទ

១. ការប្រើពាក្យផ្តើម៖

ក. ពាក្យគន្លឹះសំរាប់ប្រើក្នុងការផ្តើមលិខិត៖

| ពាក្យផ្តើម | ចំណាំ |
|---|---|
| តបតាមកម្មវត្ថុខាងលើ | |
| តបតាមកម្មវត្ថុ និងយោងខាងលើ | ក្នុងករណីមានយោង |
| អាស្រ័យតាមកម្មវត្ថុ ខាងលើ | |
| អាស្រ័យតាមកម្មវត្ថុ និងយោងខាងលើ | ក្នុងករណីមានយោង |
| តតាមកម្មវត្ថុខាងលើ | |

*<u>សូមមើលទំរង់ពាក្យគន្លឹះ ផ្តើមលិខិត (ឧបសម្ព័ន្ធទី៣)</u>*

## ជំហានទី ១០ ៖ ឃ្លាបញ្ចប់ខ្លឹមសារលិខិត

- ឃ្លាបញ្ចប់ខ្លឹមសារលិខិត មានលក្ខណៈខុសៗគ្នាទៅតាម ឋានានុក្រមរបស់អ្នកទទួល។
- បើអ្នកទទួលមានឋានានុក្រមខ្ពស់ ការសរសេរឃ្លាថ្លែងការគោរពត្រូវតែមានភាពខ្ពង់ខ្ពស់ដែរ។
- ឧទាហរណ៍៖

  នាយករដ្ឋមន្ត្រី = សូមសម្តេចមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

  ប្រធានការិយាល័យ = សូមលោក ទទួលនូវរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

ពាក្យគន្លឹះ ប្រើប្រាស់ក្នុង ឃ្លាបញ្ចាប់ខ្លឹមសារលិខិត៖

| ពាក្យបញ្ចប់ (នៅខាងដើមប្រយោគ) | ពាក្យនៅកណ្តាល | ពាក្យបញ្ចប់ (នៅខាងចុងប្រយោគ) |
|---|---|---|
| អាស្រ័យដូចបានជម្រាបជូនខាងលើ | .................. | សូមមេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះ ។ |
| ហេតុដូចបានជម្រាបជូនខាងលើនេះ | .................. | មេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះ។ |
| អាស្រ័យហេតុនេះ | .................. | មេត្តាអនុញ្ញាតតាមការគួរ។ |
| អាស្រ័យហេតុដូចបានបញ្ជាក់ខាងលើនេះ | .................. | អនុញ្ញាតតាមការគួរ។ |
| ជាចុងបញ្ចប់ | .................. | មេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះ។ |

*សូមមើលទំរង់ពាក្យគន្លឹះ បញ្ចាប់ខ្លឹមសារលិខិត (ឧបសម្ព័ន្ធទី៤)*

## ជំហានទី ១១ ៖ ឃ្លាថ្លែងការគោរព

- ឃ្លាថ្លែងការគោរពត្រូវប្រើនៅពេលដែល បានសរសេរ ឃ្លាបញ្ចាប់ខ្លឹមសារលិខិត រួចហើយ
- ការប្រើប្រាស់ឃ្លាបញ្ចាប់ខ្លឹមសារលិខិត ត្រូវរើសទៅតាម ឋានានុក្រមរបស់អ្នកទទួលលិខិតផងដែរ។
- ឧទាហរណ៍៖

  នាយករដ្ឋមន្ត្រី =

  សូមសម្តេចមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

  នាយកដ្ឋាន = សូមលោក

  ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

*សូមមើលទំរង់ពាក្យគន្លឹះឃ្លាថ្លែងការគោរព (ឧបសម្ព័ន្ធទី ៥)*

## ជំហានទី ១២ ៖ ហត្ថលេខា

- ដាក់តួនាទី និង ឈ្មោះនៅពីក្រោមដោយចុះបន្ទាត់ចំនួន ៤ដង។
- ក្នុងករណីដែលមានអ្នកជំនួស ត្រូវ សរសេរ អក្សរ "ជ." ពីមុខតួនាទី ។ អ្នកដែលចុះហត្ថលេខាជំនួសត្រូវដាក់តួនាទី ពីក្រោម តួនាទីនាយកប្រតិបត្តិ។
- អក្សរកាត់ដាក់ពីមុខតួនាទី៖
    a. " ជ." = ជំនួស (ពេញនាយក មានបេសកកម្មចុះខេត្ត/អវត្តមាន)
    b. " ត.ប" = តាមបញ្ជា (អនុវត្តតាមបទបញ្ជារបស់នាយក)
- មានត្រាឈ្មោះសំរាប់វាយនៅពេល ចុះហត្ថលេខារួច
- ការបោះត្រាស្ថាប័ន ត្រូវបោះ ត្រឹម ១/៣ លើហត្ថលេខា ដោយមិនអោយត្រាជាន់លើឈ្មោះ។

## ជំហានទី ១៣ ៖ ការចំលងជូន

- ក្នុងករណីដែលមានចំលងអោយស្ថាប័ន រឺបុគ្គលណាផ្សេងៗទៀត ដឹងលឺ មានវិធានការណ៍បន្ត រឺអនុវត្ត លិខិតបទដ្ឋាន នោះត្រូវចំលងជូនបុគ្គលនោះ។ ឧទាហរណ៍៖
    - "ដើម្បីអនុវត្ត"
    - "ដើម្បីជាពត៌មាន"
    - "ដើម្បីចាត់វិធានការណ៍"
    - "ដើម្បីសហការ"
    - ។ល។

- បន្ទាប់មក ជាចុងក្រោយ ត្រូវសរសេរឃ្លា "ឯកសារ និងកាល្បវត្តិន៍" នូវរាល់ពេលរៀបចំលិខិតរដ្ឋបាល ដើម្បីរក្សាកំកល់ទុកឯកសារនៅស្ថាប័ន។

## ឧបសម្ព័ន្ធ ៖

**ឧបសម្ព័ន្ធទី១៖ ប្លង់លិខិតរដ្ឋបាល**

១ ៣

២

No……………….…..CDPO

រាជធានីភ្នំពេញ, ថ្ងៃទី ខែធ្នូ ឆ្នាំ២០១២

**នាយកប្រតិបត្តិអង្គការ**.............

៥

**សូមគោរពជូន**

៤

**ឯកឧត្តម បណ្ឌិត អ៊ិត សំហេង**

៦

៧

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**

**កម្មវត្ថុ៖** សំណើសុំគោរពអញ្ជើញ **ឯកឧត្តមបណ្ឌិត** ជាហត្ថលេខីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីចុះហត្ថលេខាលើ អនុស្សារណយោគយល់រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៨ និងអង្គការ...........នាខែ...... ឆ្នាំ ......នៅក្រសួងសង្គមកិច្ច។

**យោង៖** លិខិត XXX/១២ អ.ព.ក ចុះថ្ងៃទី XX ខែ XX ឆ្នាំ XXរបស់អង្គការ ..........ស្តីពី

៩ សំណើសុំចុះអនុស្សារណជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបដល់ **ឯកឧត្តមបណ្ឌិត** មេត្តាជ្រាបថា អង្គការ.............បាន ដាក់សំណើជូន ដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបន្តនូវអនុស្សារណយោគយល់រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការ......................។ អង្គការ...................... សូមការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមបណ្ឌិត** ជាហត្ថលេខីដ៏ខ្ពង់ខ្ពស់ក្នុងពិធីចុះហត្ថលេខាលើអនុស្សារណយោគយល់នេះ។

១០ អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម **ឯកឧត្តមបណ្ឌិត** មេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះ។

១១ សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

១២

**នាយកប្រតិបត្តិ**.

ចំលងជូន៖ ១៣

ឯកសារ និងកាលប្បវត្តិ៍

..................

ឧបសម្ព័ន្ធទី២៖ រង់នៃការប្រើប្រាស់ពាក្យ (គោរព)*តាមឋានានុក្រមនៃអ្នកទទួល*

# ទំរង់នៃការប្រើប្រាស់ពាក្យ (គោរព) តាមឋានានុក្រមនៃអ្នកទទួល

| មុខងារសាធារណៈ | ពាក្យ "គោរព" ត្រូវប្រើ | ងារ បូក ឈ្មោះ | មុខតំណែង បូក ស្ថាប័ន |
|---|---|---|---|
| នៅក្នុងព្រះមហាក្សត្រ | | | |
| ព្រះមហាក្សត្រ | សូមក្រាបបង្គំទូលថ្វាយ | **ព្រះករុណា ព្រះមហាក្សត្រ នរោត្តម សីហមុនី** | ព្រះប្រមុខរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា |
| សម្តេច | សូមគោរពជូន | សម្តេច ព្រះចៅហ្វាវាំង **គង់ សំអុល** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងព្រះបរមរាជវាំង |
| នៅក្នុងជួរព្រះសង្ឃ | | | |
| សម្តេចសង្ឃ | សូមថ្វាយបង្គំ | សម្តេចសង្ឃរាជ គណៈមហាកនិកាយ ..... | |
| ចៅអធិការ | សូមថ្វាយបង្គំ | ព្រះចៅអធិការ **ផាន់ នួន** | |
| នៅក្នុងជួររាជរដ្ឋាភិបាល | | | |
| នាយករដ្ឋមន្ត្រី | សូមគោរពជូនចំពោះ | សម្តេច អគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** | នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា |
| រដ្ឋមន្ត្រី | សូមគោរពជូន | ឯកឧត្តម បណ្ឌិត **អ៊ិត សំហេង** | រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច និង អតីតយុទ្ធជន និងយុវនីតិសម្បទា |
| រដ្ឋលេខាធិការ | សូមគោរពជូន | ឯកឧត្តម **សែម សុខា** | រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា |
| អនុរដ្ឋលេខាធិការ | សូមគោរពជូន | ឯកឧត្តម ............ | អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា |
| អគ្គនាយកដ្ឋាន | គោរពជូន | ឯកឧត្តម ............ | អគ្គនាយក អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច |

| | | | |
|---|---|---|---|
| | | | និងអតីតយុទ្ធជន និងយុវនីតិសម្បទា |
| នាយកដ្ឋាន | គោរពមក | លោក ................. | នាយក នាយកដ្ឋាន សុខមាលភាពជនពិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា |
| ប្រធានការិយាល័យ | សូមជម្រាបជូន | លោក ...................... | ប្រធានការិយាល័យ សុខមាលភាពជនពិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា |
| អនុប្រធានការិយាល័យ | សូមជម្រាបជូន | លោកស្រី ...................... | អនុប្រធាន ការិយាល័យ សុខមាលភាពជនពិការ ក្រសួងសង្គមកិច្ចនិងអតីតយុទ្ធជន និងយុវនីតិសម្បទា |
| ប្រធានមន្ទីរ ខេត្ត/រាជធានី | សូមជម្រាបជូន | លោកស្រី ...................... | ប្រធានមន្ទីរ សង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តសៀមរាប |
| នៅក្នុងជួរអង្គការ | | | |
| នាយកប្រតិបត្តិ | សូមគោរពជូន | លោក ............. | នាយកប្រតិបត្តិ អង្គការភូមិយើង |
| នាយកប្រតិបត្តិស្តីទី | សូមគោរពជូន | លោកស្រី  ............. | នាយិកាប្រតិបត្តិស្តីទី អង្គការភូមិយើង |
| ប្រធានអង្គការ | សូមគោរពជូន | លោកស្រី ............. | ប្រធានអង្គការស្ត្រីអភិវឌ្ឍន៍ |
| ប្រធានកម្មវិធី | គោរពជូន | លោក ............. | ប្រធានកម្មវិធី តស៊ូមតិ អង្គការស្ត្រីអភិវឌ្ឍន៍ |

ឧបសម្ព័ន្ធទី៣៖ ទំរង់ពាក្យគន្លឹះផ្តើមលិខិត

# ទំរង់ពាក្យគន្លឹះផ្តើមលិខិត

(Key Word Starting Letter Template)

| មុខងារសាធារណៈ | ពាក្យ "គោរព" ត្រូវប្រើ | ងារ បូក ឈ្មោះ | មុខតំណែង បូក ស្ថាប័ន | ពាក្យផ្តើម |
|---|---|---|---|---|
| នៅក្នុងព្រះមហាក្សត្រ | | | | |
| ព្រះមហាក្សត្រ | សូមក្រាបបង្គំទូលថ្វាយ | **ព្រះករុណា ព្រះមហាក្សត្រ នរោត្តម សីហមុនី** | ព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា | តបតាមកម្មវត្ថុខាងលើ **ខ្ញុំព្រះករុណា** មាន**ព្រះមហាកិត្តិ យសដ៏ឧត្តុងឧត្តមជាទីបំផុត សូមលំអោនកាយក្រាបថ្វាយបង្គំ ទូលថ្វាយ** ព្រះករុណា ព្រះមហាក្សត្រ **ជីវិត តំកល់លើត្បូង ជាទីគោរពសក្ការៈ ព្រះមេត្តា សណ្តាប់ដ៏ខ្ពង់ខ្ពស់** ........(ពន្យល់ខ្លឹមសារ) |
| សម្តេច | សូមគោរពជូន | សម្តេច ព្រះចៅហ្វាវាំង **គង់ សំអុល** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង | តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមាន**កិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពជម្រាបជូន** សម្តេច ***មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់*** ........(ពន្យល់ខ្លឹមសារ) |
| នៅក្នុងជួរព្រះសង្ឃ | | | | |
| សម្តេចសង្ឃ | សូមថ្វាយបង្គំ | សម្តេចសង្ឃរាជ គណៈមហាកនិកាយ | | តបតាមកម្មវត្ថុខាងលើ ខ្ញុំព្រះករុណាមាន**កិត្តិយសដ៏ខ្ពង់ ខ្ពស់** |

| មុខងារសាធារណៈ | ពាក្យ "គោរព" ត្រូវប្រើ | ងារ បូក ឈ្មោះ | មុខតំណែង បូក ស្ថាប័ន | ពាក្យផ្ដើម |
|---|---|---|---|---|
| | | ..... | | **<u>សូមក្រាបថ្វាយបង្គំ ទូលថ្វាយ</u>**សម្ដេច **<u>មេត្តាសណ្ដាប់ដ៏ខ្ពង់ខ្ពស់</u>**........(ពន្យល់ខ្លឹមសារ) |
| ចៅអធិការ | សូមថ្វាយបង្គំ | ព្រះចៅអធិការ **ផាន់ នួន** | | តបតាមកម្មវត្ថុខាងលើ ខ្ញុំព្រះករុណាមាន **<u>កិត្តិយសសូម ក្រាបថ្វាយបង្គំ ទូលថ្វាយ</u>** ព្រះចៅអធិការ **<u>មេត្តាសណ្ដាប់</u>** ........(ពន្យល់ខ្លឹមសារ) |
| នៅក្នុងជួររាជរដ្ឋាភិបាល | | | | |
| នាយករដ្ឋមន្ត្រី | សូមគោរពជូនចំពោះ | សម្ដេច អគ្គមហា សេនាបតី តេជោ **ហ៊ុន សែន** | នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមាន **<u>កិត្តិយសដ៏ខ្ពង់ខ្ពស់</u> <u>សូមគោរពជម្រាបជូន</u>** សម្ដេច **<u>មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់</u>**........(ពន្យល់ខ្លឹមសារ) |
| រដ្ឋមន្ត្រី | សូមគោរពជូន | ឯកឧត្តម បណ្ឌិត **អ៊ិត សំហេង** | រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមាន **<u>កិត្តិយសដ៏ខ្ពង់ខ្ពស់</u> <u>សូមគោរពជម្រាបជូន</u>** **ឯកឧត្តម បណ្ឌិត** **<u>មេត្តា ជ្រាបថា</u>** ........(ពន្យល់ខ្លឹមសារ) |
| រដ្ឋលេខាធិការ | សូមគោរពជូន | ឯកឧត្តម **សែម សុខា** | រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមាន**<u>កិត្តិយស សូមគោរពជម្រាបជូន</u>** ឯកឧត្តម **<u>មេត្តាជ្រាបថា</u>** ........(ពន្យល់ខ្លឹមសារ) |
| អនុរដ្ឋលេខាធិ | សូមគោរពជូន | ឯកឧត្តម **............** | អនុរដ្ឋលេខាធិការ ក្រសួង | តបតាមកម្មវត្ថុ និងយោងខាងលើ |

| មុខងារសាធារណៈ | ពាក្យ "គោរព" ត្រូវប្រើ | ងារ បូក ឈ្មោះ | មុខតំណែង បូក ស្ថាប័ន | ពាក្យផ្ដើម |
|---|---|---|---|---|
| ការ | | | សង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | **ខ្ញុំបាទមានកិត្តិយស** **សូមជម្រាបជូន** ឯកឧត្តម **មេត្តាជ្រាបថា** ........(ពន្យល់ខ្លឹមសារ) |
| អគ្គនាយកដ្ឋាន | គោរពជូន | ឯកឧត្តម ............ | អគ្គនាយក អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | តបតាមកម្មវត្ថុ និងយោងខាងលើ **ខ្ញុំបាទមានកិត្តិយស សូមជម្រាបជូន**ឯកឧត្តម **ជ្រាបថា** ........(ពន្យល់ខ្លឹមសារ) |
| នាយកដ្ឋាន | គោរពមក | លោក ................. | នាយក នាយកដ្ឋានសុខមាលភាពជនពិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | តបតាមកម្មវត្ថុ និងយោងខាងលើ **ខ្ញុំមានកិត្តិយស** **ជម្រាបជូន** លោក **មេត្តាជ្រាបថា** ........(ពន្យល់ខ្លឹមសារ) |
| ប្រធានការិយាល័យ | សូមជម្រាបជូន | លោក ...................... | ប្រធានការិយាល័យ សុខមាលភាពជនពិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | តបតាមកម្មវត្ថុ និងយោងខាងលើ **ខ្ញុំសូមជម្រាបជូន** លោក **ជ្រាបថា** ........(ពន្យល់ខ្លឹមសារ) |
| អនុប្រធានការិយាល័យ | សូមជម្រាបជូន | លោកស្រី ...................... | អនុប្រធាន ការិយាល័យ សុខមាលភាពជនពិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | តបតាមកម្មវត្ថុ និងយោងខាងលើ **ខ្ញុំសូមជម្រាបជូន** លោកស្រី **ជ្រាបថា** ........(ពន្យល់ខ្លឹមសារ) |

| មុខងារសាធារណៈ | ពាក្យ "គោរព" ត្រូវប្រើ | ងារ បូក ឈ្មោះ | មុខតំណែង បូក ស្ថាប័ន | ពាក្យផ្ដើម |
|---|---|---|---|---|
| ប្រធានមន្ទីរ ខេត្ត/រាជធានី | សូមជម្រាបជូន | លោកស្រី ...................... | ប្រធានមន្ទីរ សង្គមកិច្ច និង អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តសៀមរាប | តបតាមកម្មវត្ថុ និងយោងខាងលើ **ខ្ញុំសូមជម្រាបជូន** លោកស្រី **ជ្រាបថា** ........(ពន្យល់ខ្លឹមសារ) |
| នៅក្នុងជួរអង្គការ | | | | |
| នាយកប្រតិបត្តិ | សូមគោរពជូន | លោក ............. | នាយកប្រតិបត្តិ អង្គការភូមិយើង | តបតាមកម្មវត្ថុ និងយោងខាងលើ **ខ្ញុំមានកិត្តិយស សូមជម្រាបជូន**លោក **មេត្តាជ្រាបថា** ........(ពន្យល់ខ្លឹមសារ) |
| នាយកប្រតិបត្តិស្ដីទី | សូមគោរពជូន | លោកស្រី ............. | នាយិកាប្រតិបត្តិស្ដីទី អង្គការភូមិយើង | តបតាមកម្មវត្ថុ និងយោងខាងលើ **ខ្ញុំមានកិត្តិយស សូមជម្រាបជូន**លោកស្រី **មេត្តាជ្រាបថា** ........(ពន្យល់ខ្លឹមសារ) |
| ប្រធានអង្គការ | សូមគោរពជូន | លោកស្រី ............ | ប្រធានអង្គការស្ត្រីអភិវឌ្ឍន៍ | តបតាមកម្មវត្ថុ និងយោងខាងលើ **ខ្ញុំមានកិត្តិយស សូមជម្រាបជូន**លោកស្រី **មេត្តាជ្រាបថា** ........(ពន្យល់ខ្លឹមសារ) |
| ប្រធានកម្មវិធី | គោរពជូន | លោក ............ | ប្រធានកម្មវិធី តស៊ូមតិ អង្គការស្ត្រីអភិវឌ្ឍន៍ | តបតាមកម្មវត្ថុ និងយោងខាងលើ **ខ្ញុំមានកិត្តិយស សូមជម្រាបជូន**លោក **ជ្រាបថា** ........(ពន្យល់ខ្លឹមសារ) |

ឧបសម្ព័ន្ធទី៤៖ ពាក្យគន្លឹះបញ្ចប់ខ្លឹមសារលិខិត

# ពាក្យគន្លឹះបញ្ចប់ខ្លឹមសារលិខិត

(Key Word Ending Letter Meaning Template)

| មុខងារសាធារណៈ | ងារ បូក ឈ្មោះ | មុខតំណែង បូក ស្ថាប័ន | ពាក្យបញ្ចប់សេចក្តី |
|---|---|---|---|
| នៅក្នុងព្រះមហាក្សត្រ | | | |
| ព្រះមហាក្សត្រ | **ព្រះករុណា ព្រះមហាក្សត្រ នរោត្តម សីហមុនី** | ព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា | ជាចុងបញ្ចាប់ **ទូលបង្គំជាខ្ញុំ ខ្ញុំព្រះករុណា សូមព្រះ មេត្តាប្រោសប្រទានសេចក្តីអនុញ្ញាត ដោយសេចក្តី ព្រះមេត្តា មហាតិគុណដ៏ខ្ពង់ខ្ពស់ និងឧត្តុងឧត្តម ជាទីបំផុត**។ |
| សម្តេច | សម្តេច ព្រះចៅហ្វាវាំង **គង់ សំអុល** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម សម្តេច **មេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត**។ |
| នៅក្នុងជួរព្រះសង្ឃ | | | |
| សម្តេចសង្ឃ | សម្តេចសង្ឃរាជ គណៈមហាកនិកាយ ..... | | អាស្រ័យដូចបានទូលថ្វាយ ខាងលើនេះសូម សម្តេច មេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត។ |
| ចៅអធិការ | ព្រះចៅអធិការ **ផាន់ នួន** | | អាស្រ័យដូចបានទូលថ្វាយ ខាងលើនេះសូម ព្រះចៅ អធិការ **មេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះដ៏ជ្រាលជ្រៅបំផុត**។ |

| **មុខងារសាធារណៈ** | **ងារ បូក ឈ្មោះ** | **មុខតំណែង បូក ស្ថាប័ន** | **ពាក្យបញ្ចប់សេចក្តី** |
|---|---|---|---|
| នៅក្នុងជួររាជរដ្ឋាភិបាល | | | |
| នាយករដ្ឋមន្ត្រី | សម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម សម្តេច **មេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត**។ |
| រដ្ឋមន្ត្រី | ឯកឧត្តម បណ្ឌិត **អ៊ិត សំហេង** | រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម ឯកឧត្តមបណ្ឌិត មេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត។ |
| រដ្ឋលេខាធិការ | ឯកឧត្តម **សែម សុខា** | រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម ឯកឧត្តម មេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។ |
| អនុរដ្ឋលេខាធិការ | ឯកឧត្តម ............ | អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម ឯកឧត្តមមេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។ |
| អគ្គនាយកដ្ឋាន | ឯកឧត្តម ............ | អគ្គនាយក អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម ឯកឧត្តមមេត្តាអនុញ្ញាតដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។ |
| នាយកដ្ឋាន | លោក ................. | នាយក នាយកដ្ឋានសុខមាលភាពជនពិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម លោក អនុញ្ញាតដោយសេចក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។ |

| មុខងារសាធារណៈ | ងារ បូក ឈ្មោះ | មុខតំណែង បូក ស្ថាប័ន | ពាក្យបញ្ចប់សេចក្តី |
|---|---|---|---|
| | | និងយុវនីតិសម្បទា | |
| ប្រធានការិយាល័យ | លោក ...................... | ប្រធានការិយាល័យ សុខមាលភាពជនពិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម លោក អនុញ្ញាតដោយការអនុគ្រោះ។ |
| អនុប្រធានការិយាល័យ | លោកស្រី ...................... | អនុប្រធាន ការិយាល័យ សុខមាលភាពជនពិការ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម លោកស្រី អនុញ្ញាតដោយអនុគ្រោះ។ |
| ប្រធានមន្ទីរ ខេត្ត/រាជធានី | លោកស្រី ...................... | ប្រធានមន្ទីរ សង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តសៀមរាប | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម លោកស្រី អនុញ្ញាតដោយការអនុគ្រោះ។ |
| នៅក្នុងជួរអង្គការ | | | |
| នាយកប្រតិបត្តិ | លោក .............. | នាយកប្រតិបត្តិ អង្គការភូមិយើង | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម លោក_នាយកប្រតិបត្តិ អនុញ្ញាតដោយសេចក្តីអនុគ្រោះ។ |
| នាយកប្រតិបត្តិស្តីទី | លោកស្រី .............. | នាយិកាប្រតិបត្តិស្តីទី អង្គការភូមិយើង | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម លោកស្រី_នាយិកាប្រតិបត្តិ អនុញ្ញាតដោយសេចក្តីអនុគ្រោះ។ |

| មុខងារសាធារណៈ | ងារ បូក ឈ្មោះ | មុខតំណែង បូក ស្ថាប័ន | ពាក្យបញ្ចាប់សេចក្តី |
|---|---|---|---|
| ប្រធានអង្គការ | លោកស្រី ............ | ប្រធានអង្គការស្ត្រីអភិវឌ្ឍន៍ | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម លោកស្រី ប្រធាន <u>អនុញ្ញាតដោយសេចក្តីអនុគ្រោះ។</u> |
| ប្រធានកម្មវិធី | លោក ............ | ប្រធានកម្មវិធី តស៊ូមតិ អង្គការស្ត្រីអភិវឌ្ឍន៍ | អាស្រ័យដូចបានជម្រាបជូនខាងលើនេះសូម លោក <u>អនុញ្ញាតដោយការអនុគ្រោះ។</u> |

**ឧបសម្ព័ន្ធទី៥៖ ឃ្លាថ្លែងការគោរព**

# ឃ្លាថ្លែងការគោរព

(Respective Sentence Template)

| មុខងារសាធារណៈ | ងារ បូក ឈ្មោះ | ឃ្លាថ្លែងការគោរព |
|---|---|---|
| នៅក្នុងព្រះមហាក្សត្រ | | |
| ព្រះមហាក្សត្រ | **ព្រះករុណា ព្រះមហាក្សត្រ នរោត្តម សីហមុនី** | សូមព្រះករុណាជីវិតកំកល់លើត្បូង ព្រះមេត្តាទទួលនូវសេចក្តីក្រាបបង្គំទូលថ្វាយដ៏ឧត្តុង្គ ឧត្តមបំផុតអំពី ទូលព្រះបង្គំ៕ |
| សម្តេច | សម្តេច ព្រះចៅហ្វាវាំង **គង់ សំអុល** | សូមសម្តេចមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។ |
| នៅក្នុងជួរព្រះសង្ឃ | | |
| សម្តេចសង្ឃ | សម្តេចសង្ឃរាជ គណៈមហានិកាយ ..... | សូមសម្តេចមេត្តាទទួលនូវការបង្គំគោរពសក្ការៈដ៏ខ្ពង់ខ្ពស់អំពី ខ្ញុំករុណា។ |
| ចៅអធិការ | ព្រះចៅអធិការ **ផាន់ នួន** | សូមសម្តេចមេត្តាទទួលនូវការបង្គំគោរពសក្ការៈ អំពី ខ្ញុំករុណា។ |
| នៅក្នុងជួររាជរដ្ឋាភិបាល | | |
| នាយករដ្ឋមន្ត្រី | សម្តេច អគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** | សូមសម្តេចមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។ |
| រដ្ឋមន្ត្រី | ឯកឧត្តម បណ្ឌិត **អ៊ិត សំហេង** | សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។ |
| រដ្ឋលេខាធិការ | ឯកឧត្តម **សែម សុខា** | សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។ |
| អនុរដ្ឋលេខាធិការ | ឯកឧត្តម ............. | សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។ |
| អគ្គនាយកដ្ឋាន | ឯកឧត្តម ............. | សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។ |

| មុខងារសាធារណៈ | ងារ បូក ឈ្មោះ | ឃ្លាថ្លែងការគោរព |
|---|---|---|
| នាយកដ្ឋាន | លោក .................. | សូមលោក ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។ |
| ប្រធានការិយាល័យ | លោក ...................... | សូមលោក ទទួលនូវរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។ |
| អនុប្រធានការិយាល័យ | លោកស្រី ...................... | សូមលោកស្រី ទទួលនូវរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។ |
| ប្រធានមន្ទីរ ខេត្ត/រាជធានី | លោកស្រី ...................... | សូមលោក ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។ |
| នៅក្នុងជួរអង្គការ | | |
| នាយកប្រតិបត្តិ | លោក .............. | សូមលោកមេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។ |
| នាយកប្រតិបត្តិស្ដីទី | លោកស្រី .............. | សូមលោកស្រីមេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។ |
| ប្រធានអង្គការ | លោកស្រី ............. | សូមលោកប្រធាន មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។ |
| ប្រធានកម្មវិធី | លោក ............. | សូមលោកមេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំបាទ។ |

ផលិតដោយ គាំទ្រថវិកាដោយ

រក្សាសិទ្ធិដោយ អ.ព.ក